# រាជរដ្ឋាភិបាលកម្ពុជា

## គណៈកម្មាធិការដឹកនាំការងារ
## កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# សមិទ្ធផល

## និង

# ទិសដៅ៥ឆ្នាំ

## នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**រៀបចំដោយ÷**

**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំ**

**ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** (PFMRP) គឺជាកម្មវិធីកែទម្រង់ស្នូលមួយ នៃកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីពង្រឹងអភិបាលកិច្ច និងទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ច ប្រកបដោយបរិយាប័ន្ន និងសមធម៌ដូចបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ PFMRP មានគោលដៅកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលផ្តោតលើលទ្ធផល និងវិមជ្ឈការ ស្របតាមស្តង់ដារអន្តរជាតិ។

សមិទ្ធផលរយៈពេល ៥ឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបង្ហាញនូវសមិទ្ធផលរបស់រាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភាខិតខំអនុវត្ត ព្រមទាំងកំណត់នូវបញ្ហាប្រឈម និងទិសដៅបន្តរយៈពេល ៥ឆ្នាំ សម្រាប់រាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា និងឆ្លុះបញ្ចាំងនូវសមាសធាតុគន្លឹះទាំង៤ ដែលបានកំពុងរៀបចំ និងពង្រឹងការអនុវត្តរួមមាន “**ការរៀបចំប្រព័ន្ធ, ការរៀបចំក្របខ័ណ្ឌគតិយុត្ត, ការរៀបចំយន្តការ និងការកសាងធនធានមនុស្សលើវិស័យហិរញ្ញវត្ថុសាធារណៈ**”។ ទន្ទឹមនឹងនេះ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានសុទិដ្ឋិនិយម និងវាយតម្លៃសមិទ្ធផលសម្រេចបានរយៈពេល ៥ឆ្នាំ ជារួមថា÷ (១).ភាពជឿទុកចិត្តនៃថវិកានៅតែរក្សាបានជាសារវន្ត, (២).ប្រព័ន្ធគណនេយ្យភាពបាននិងកំពុងកសាងតាមរយៈការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ដំណាក់កាលទី២ ជាមួយនឹងភាពប្រុងប្រយ័ត្នខ្ពស់, (៣).ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធីជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំ និងកំណត់ការផ្លាស់ប្តូរប្រព័ន្ធថវិកាកម្ពុជា, (៤).ការរៀបចំ និងដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ ជា សមាសធាតុសំខាន់សម្រាប់កំណត់ទិសដៅនៃគណនេយ្យភាពសមិទ្ធកម្ម និង (៥).ការរៀបចំប្រព័ន្ធលើកទឹកចិត្ត នឹងជំរុញការធ្វើស្ថាប័ននីយកម្មឱ្យស្របតាមទិសដៅនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

បន្ថែមពីនេះ ក្នុងក្របខ័ណ្ឌសេដ្ឋកិច្ច រាជរដ្ឋាភិបាលសម្រេចបានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំក្នុងរង្វង់ ៧% ព្រមទាំងសម្រេចបាននូវបង្គោលគោរចជាប្រវត្តិសាស្ត្រ គឺការឆ្លងពីប្រទេសមានចំណូលមធ្យមកម្រិតទាបជាផ្លូវការនៅឆ្នាំ២០១៥ និងត្រូវបានប្រសិទ្ធិនាមថាជា “**ខ្លាសេដ្ឋកិច្ចនៅអាស៊ី**” នៅឆ្នាំ ២០១៦។ រីឯ ភាពគ្មានការងារធ្វើស្ថិតក្នុងអត្រា ០,៣% ភាពក្រីក្រតោកយ៉ាកត្រូវបានលុបបំបាត់ចោលទាំងស្រុងក្នុងឆ្នាំ ២០១៧ និងប្រាក់ចំណូលក្នុងមនុស្សម្នាក់កើនពី ១ ០៤២ ដុល្លារអាមេរិកក្នុងឆ្នាំ២០១៣ ដល់ប្រមាណ ១ ៤២៧ ដុល្លារអាមេរិកក្នុងឆ្នាំ ២០១៧ ។

ចំណែកឯក្នុងក្របខ័ណ្ឌកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលនៅតែមានភាពរឹងមាំ ដែលចំណូលមានការកើនឡើងក្នុងចន្លោះ ១៥%-២០% ក្នុងមួយឆ្នាំ ក្នុងរយៈពេល ៥ឆ្នាំ ចុងក្រោយ ហើយចំណូលចន្តថវិកាជាតិបានកើនឡើងពីប្រមាណ ១៥,០៦% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០១៣ ដល់ ១៩,៦៤% ក្នុងឆ្នាំ ២០១៧ ។ រីឯ ថវិកាចំណាយបានកើនឡើងប្រមាណ ១,៨ ដង ហើយការវិភាជថវិកាត្រូវបានគិតគូលើវិស័យអាទិភាពសំខាន់ៗ និងការអនុវត្តថវិកាផ្នែកចំណាយក៏កាន់តែមានប្រសិទ្ធភាព ទាំងកម្រិតវិភាជន៍ និងកម្រិតប្រតិបត្តិការ ។

## ក. សមិទ្ធផលសម្រេចបានក្នុងរយៈពេល ៥ ឆ្នាំ

សមិទ្ធផលរយៈពេល ៥ ឆ្នាំ ត្រូវបានបង្ហាញក្នុងទិដ្ឋភាពចំនួន ២ លើទិដ្ឋភាពទូទៅនៃ PFMRP ទាំងភាពខ្លាំងនិងភាពខ្សោយនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដោយប្រើប្រាស់នូវ **ក្របខ័ណ្ឌចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ** (PEFA) **ឆ្នាំ២០១១** ដូចដ្យាក្រាមសង្ខេបជូនខាងក្រោមនេះ÷


















ទន្ទឹមនឹងនេះ លទ្ធផលវាយតម្លៃ PEFA ឆ្នាំ២០១៧ ឆ្លុះបញ្ចាំងថា ប្រព័ន្ធ PFM គឺមានភាពប្រសើរជាងមុន លើប្រសិទ្ធភាពនៃការអនុវត្តថវិកា, ការពង្រឹងរដ្ឋបាលប្រមូលចំណូល, តម្លាភាពថវិកា និងលទ្ធកម្មសាធារណៈ និងប្រសិទ្ធភាពនៃការគ្រប់គ្រងបៀវត្ស។

## ខ.ទិសដៅរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បូរណភាពនៃការគោរពវិន័យថវិកា
- ប្រសិទ្ធភាពនៃថវិកា ទាំងក្នុងផ្នែកវិភាជន៍, ទាំងក្នុងផ្នែកប្រតិបត្តិការ
- ស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ

## គ.ទិសដៅនៃ PFMRP សម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- រៀបចំក្របខ័ណ្ឌគោលនយោបាយពន្ធរយៈពេលមធ្យមឆ្នាំ ២០១៩-២០២៣
- អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥
- ពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធ FMIS ស្របតាមផែនការយុទ្ធសាស្ត្រដំណាក់កាលទី២
- រៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យម (MTFF) និងក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF)
- ធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ ដើម្បីឱ្យស្របតាមបរិបទប្រព័ន្ធថវិកាថ្មី
- បញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- រៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិឆ្នាំ២០១៨-២០២៥
- រៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥
- រៀបចំក្របខ័ណ្ឌវិនិយោគសាធារណៈ និងភាពជាដៃគូរវាងរដ្ឋ និងឯកជន
- រៀបចំផែនទីចង្អុលបង្ហាញផ្លូវគណនេយ្យបង្គរ
- រៀបចំមគ្គុទេសក៍គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរាជរដ្ឋាភិបាល
- រៀបចំមូលនិធិនៃ PFMRP គ្រប់ជ្រុងជ្រោយ និងកសាងសមត្ថភាពធនធានមនុស្សលើវិស័យហិរញ្ញវត្ថុសាធារណៈ

## ឃ. ទិសដៅនៃ PFMRP សម្រាប់ក្រសួង ស្ថាប័ន

ជាទិសដៅសម្រាប់ការចូលរួមការអនុវត្ត PFMRP ក្នុងឆ្នាំ២០១៨--២០២៣ ក្រសួង ស្ថាប័ន គួរផ្តោតលើសកម្មភាពអាទិភាពដូចខាងក្រោម÷

**ហិរញ្ញវត្ថុសាធារណៈ:**
- ប្រសិទ្ធភាពការប្រមូលចំណូល និងចំណាយ
- តម្លាភាពលទ្ធកម្មសាធារណៈ
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- សវនកម្ម និងអធិការកិច្ច

**ថវិកាកម្មវិធី**
- ផែនការយុទ្ធសាស្ត្រថវិកា
- កែលម្អរចនាសម្ព័ន្ធស្ថាប័ន និងអង្គភាពថវិកា
- ត្រួតពិនិត្យការអនុវត្តថវិកា
- ការអនុវត្តប្រព័ន្ធFMIS និងកសាងសមត្ថភាព

ទាញយកឯកសារទន់ទីនេះ!!!
https://goo.gl/hmvXYa
ជាន់ទី៧ អគារ "គ" នៃសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
(+៨៥៥) ៨៥ ៧៧៧ ៩២០
gsc@pfm.gov.kh
www.pfm.gov.kh